ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការ
ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
លេខៈ ១៩៣/០៩ គ.ទ.ក.សរ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០០៩

**ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**ជម្រាបជូន**

**ឯកឧត្តម លោក លោកស្រី សាកលវិទ្យាធិការ នាយក នាយិការ នៃគ្រឹះស្ថានឧត្តមសិក្សា**

**កម្មវត្ថុៈ** ការបញ្ចូលកម្មវិធីសិក្សាបន្ថែមសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

**យោងៈ** លិខិតលេខ១៣៩៦ សជណ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

តបតាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សូមជម្រាបជូន ឯកឧត្តម លោក លោកស្រី សាកលវិទ្យាធិការ នាយក នាយិការ នៃគ្រឹះស្ថានឧត្តមសិក្សា ជ្រាបថា គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ចូលកម្មវិធីសិក្សាបន្ថែមសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នូវមុខវិជ្ជា ដូចខាងក្រោមៈ

១. វប្បធម៌អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ

២. ចរាចរ

៣. គ្រឿងញៀន

៤. ជំងឺអេដស៍

៥. ប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (របបប៉ុលពត)

៦. បញ្ហាប្រឈមនាពេលបច្ចុប្បន្ន។

ចំពោះ វប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ និងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (របបប៉ុលពត) គ្រឹះស្ថានឧត្តមសិក្សា ត្រូវពិនិត្យលើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដែលកំពុងអនុវត្តបច្ចុប្បន្ន។ ក្នុងករណី ពុំទាន់មានខ្លឹមសារខាងលើក្នុងកម្មវិធីសិក្សាទេ គ្រឹះស្ថានឧត្តមសិក្សា ត្រូវធ្វើសំណើសុំបន្ថែមខ្លឹមសារទាំងនោះ មក គ.ទ.ក. ដើម្បីពិនិត្យ និងផ្តល់ការយល់ព្រម។

ចំពោះ ចរាចរ គ្រឿងញៀន ជំងឺអេដស៍ និងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន គ្រឹះស្ថានឧត្តមសិក្សាអាចរៀបចំសិក្ខាសាលា បទឧទ្ទេសនាម បឋកថា និងសកម្មភាពផ្សព្វផ្សាយផ្សេងៗ ដល់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដោយមានការអញ្ជើញចូលរួមពីភាគីពាក់ព័ន្ធ។

ការបញ្ចូលមុខវិជ្ជាខាងលើក្នុងកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវអនុវត្តចាប់ពីឆ្នាំសិក្សា ២០០៩-២០១០ នេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោក លោកស្រី សាកលវិទ្យាធិការ នាយក នាយិការ នៃគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ត.ប. ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**អគ្គលេខាធិការ**

**បណ្ឌិតរដ្ឋ គឹម សំណាង**

**ចម្លងជូន:**

- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងធម្មការ និងសាសនា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ឯកសារ-កាលប្បវត្តិ